# យើងជាសាសន៍បរិសុទ្ធ ជាជនបរទេស ទាំងអស់គ្នា

ព្រះគម្ពីរ យ៉ូហាន ១:១២ អានថា

**អស់អ្នកដែលទទួលព្រះអង្គ គឺអស់អ្នកដែលជឿដល់ព្រះអង្គ ព្រះអង្គប្រទានអំណាច ឱ្យបានត្រឡប់ជាកូនព្រះ**

នៅពេលដែលយើងទទួលជឿលើព្រះយេស៊ូវ យើងត្រឡប់ជាកូនចៅរបស់ទ្រង់។ នេះជាការអស្ចារ្យមួយយ៉ាងធំ ដែលអ្នកដែលពីមុនមិនស្គាល់ព្រះ រមិលគុណព្រះ ហើយជាសត្រូវរបស់ព្រះទៀត បានត្រឡប់ជាកូនវិញ។ អរព្រះគុណព្រះអង្គ!

ពាក្យ **កូនព្រះ** មានអតន័យជ្រៅ អតន័យអស្ចារ្យ តែអត្តសញ្ញាណរបស់យើងក្នុងព្រះយេស៊ូវមានអតិន័យជ្រៅជាងច្រើនទៀត។

សូមអាន ១ពេត្រុស ២:៩-១២

**9ប៉ុន្តែ អ្នករាល់គ្នាជាពូជជ្រើសរើស ជាសង្ឃហ្លួង ជាសាសន៍បរិសុទ្ធ ជាប្រជារាស្ត្រមួយសម្រាប់ព្រះអង្គផ្ទាល់ ដើម្បីឱ្យអ្នករាល់គ្នាបានប្រកាសពីកិច្ចការដ៏អស្ចារ្យរបស់ព្រះអង្គ ដែលទ្រង់បានហៅអ្នករាល់គ្នាចេញពីសេចក្តីងងឹត ចូលមកក្នុងពន្លឺដ៏អស្ចារ្យរបស់ព្រះអង្គ។**

**10ពីដើមអ្នករាល់គ្នាមិនមែនជាប្រជារាស្ត្ររបស់ព្រះទេ តែឥឡូវនេះ ជាប្រជារាស្ត្ររបស់ព្រះវិញ។ ពីដើមមិនបានទទួលសេចក្តីមេត្តាករុណាទេ តែឥឡូវនេះបានទទួលសេចក្តីមេត្តាករុណាហើយ។**

**11ពួកស្ងួនភ្ងាអើយ ខ្ញុំទូន្មានអ្នករាល់គ្នាទុកដូចជាអ្នកប្រទេសក្រៅ និងដូចជាអ្នកដែលគ្រាន់តែស្នាក់នៅបណ្តោះអាសន្នថា ចូរចៀសពីសេចក្ដីប៉ងប្រាថ្នាខាងសាច់ឈាម ដែលប្រឆាំងនឹងព្រលឹងនោះចេញ។**

**12ត្រូវប្រព្រឹត្តដោយទៀងត្រង់នៅក្នុងចំណោមពួកសាសន៍ដទៃ ដើម្បីនៅកន្លែងណាដែលគេនិយាយដើមអ្នករាល់គ្នា ទុកដូចជាមនុស្សប្រព្រឹត្តអាក្រក់ នោះគេបានឃើញអំពើល្អរបស់អ្នករាល់គ្នា ហើយលើកតម្កើងព្រះ នៅថ្ងៃដែលទ្រង់យាងមក។**

## ១៩ ពូជជ្រើសរើស (ពូចសាសន៍ដែលព្រះអង្គបានជ្រើសរើស)

ព្រះបានជ្រើសរើសយើង។ ក្នុងចំណោមមនុស្សលោក ព្រះបានជ្រើសរើសយើងដូចដែលព្រះបានជ្រើសរើសសាសន៍អ៊ីស្រអែលពីមុន។ ព្រះបានញែកយើងចេញពីមនុស្សលោកដែលនៅក្រោមមេកំណាច។

- តើអ្នកណាខ្លះនៅក្រោមមេកំណាចរាល់ថ្ងៃ? ១យ៉ូហាន ៥:១៩ អានថា

  **យើងដឹងថា យើងមកពីព្រះ ហើយលោកីយ៍ទាំងមូលដេកនៅក្នុងអំណាចរបស់មេកំណាច។**

## ១៩ ជាសង្ឃហ្លួង (ក្រុមបូជាចារ្យរបស់ព្រះមហាក្សត្រ)

យើងមានពិញសិទ្ធិចូលមកថ្វាយបង្គំព្រះ នឹងអធិស្ឋាន។ អ្នកជឿព្រះយេស៊ូវគ្មានថ្នាក់ គ្មានព្រះសង្ឃ និងប្រជាជនធម្មតាទេ។ ព្រះបានលើកយើងទាំងអស់គ្នាឡើងជាបូជាចារ្យស្មើគ្នា។

- ខុសគ្នាពីសាសនារបស់គេឆ្ងាយណាស់ គ្មានអ្នកណានៅកណ្តាលយើងនឹងព្រះទេលើកលែងតែព្រះយេស៊ូវ ជាព្រះអង្គសង្គ្រោះរបស់យើងប៉ុណ្ណោះ។

## ១៩ ជាសាសន៍បរិសុទ្ធ (ជាតិសាសន៍ដ៏បរិសុទ្ធ)

ព្រះយេស៊ូវបានលោះយើងពីទោសបាប ហើយយើងបានទទួលសេចក្តីសុចរិតរបស់ព្រះអង្គរួចហើយ។ យើងមានចិត្តថ្មី ព្រះវិញ្ញាណបរិសុទ្ធគង់នៅក្នុងយើង ហើងយើងចាប់ផ្តើមកែប្រែចិត្តដើម្បីបរិសុទ្ធឡើងក្នុងជីវិតរាល់ថ្ងៃ។

- ឥឡូវនេះ យើងលេងជាជនជាតិខ្មែរប៉ុណ្ណោះទៀតហើយ យើងនៅតែជាជនជាតិខ្មែរមែន តែឥឡូវជាបលរដ្ឋខ្មែរ ទាំងជាបលរដ្ឋសាសន៍បរិសុទ្ធរបស់ព្រះផង។ មួយទៀតភាពជាសាសន៍បរិសុទ្ធសំខាន់ជាងជ្វាយណាស់។

## ខ៩ ជាប្រជារាស្ត្រមួយសម្រាប់ព្រះអង្គផ្ទាល់ (ជាកម្មសិទ្ធិរបស់ព្រះ)

ព្រះបានជ្រើសរើសយើងដើម្បីថ្វាយសិរីល្អរបស់ទ្រង់។ កូនរបស់ព្រះ ជាកម្មសិទ្ធរបស់ព្រះ។ ឥឡូវយើងរស់នៅក្រោមច្បាប់ស្ថានសួគ៌ ក្រិតិវិន័យរបស់ព្រះយេស៊ូវ។

- ឥឡូវព្រះហឬទ័យរបស់ព្រះធំជាជៀងប្រពៃណី ឬតម្មៀមតម្លាប់ចាស់ក្នុងសង្គំ។ យើងបានកែប្រែចិត្តរួចហើយ យើងមិនគោរពលោកសង្ឃទៀតទេ មិនសែនព្រេន អុចធូប បួងសួង ជូលវត្តទៀតទេ។ ការដើរលេងស្បាយរបៀបផ្លូវបាប យើងមិនជូលរួម។ ហេតុអ្វី? យើងជាប្រជារាស្សរបស់ព្រះអង្គ។
- យើងខុសគេច្រើនណាស់ឥឡូវ។ អ្នកខ្លះនឹងស្អប់យើង ខ្លះនឹងបៀតបៀន។ ហេតុនោះហើយព្រះយេស៊ូវមានបន្ទូលថា

**អ្នកណាមិនយកឈើឆ្កាងរបស់ខ្លួន មកតាមខ្ញុំ មិនស័ក្តិសមនឹងខ្ញុំទេ(ម៉ាថាយ ១០:៣៨)។**

## ខ៩ អ្នកប្រកាសពីកិច្ចការដ៏អស្ចារ្យរបស់ព្រះអង្គ

## ខ៩ អ្នកដែលរស់នៅក្នុងពន្លឺដ៏អស្ចារ្យរបស់ព្រះអង្គ។

## ខ១០ អ្នកដែលបានបានទទួលសេចក្តីមេត្តាករុណាហើយ។

## ខ១១ អ្នកប្រទេសក្រៅ(ជនបរទេស)

អ្នកជឿលើព្រះយេស៊ូវទាំងអស់គ្នាជាជនបរទេស។ បើសិនជាយើងមានមោទនភាពនូវចំពោះប្រទេសខ្លួន មិនអីទេ! តែយើងរាប់ខ្លួនជាបរទេសជាជៀង។

- ការរស់នៅជាបរទេសមិនស្រួលទេ ប៉ុន្តែការលំបាត់នេះមានតែរយៈពេលខ្លីទេ។

## ខ១១ អ្នកដែលគ្រាន់តែស្នាក់នៅបណ្តោះអាសន្ន

សាសន៍ដ៏ពិតរបស់យើងគឺ នគររបស់ព្រះ ឋានសួគ៌។ យើងរងចាំស្រុកមួយដ៏ប្រសើជាជាង។

ព្រះគម្ពីរ ហេប្រើ ១១:១៦ អានថា

**16ប៉ុន្តែ តាមពិត គេប្រាថ្នាចង់បានស្រុកមួយដ៏ប្រសើរជាង គឺជាស្រុកមួយនៅស្ថានសួគ៌។ ហេតុនេះ ហើយបានជាព្រះទ្រង់មិនខ្មាសនឹងឲ្យគេហៅព្រះអង្គថាជាព្រះរបស់គេនោះឡើយ ដ្បិតព្រះអង្គបានរៀបចំ ទីក្រុងមួយសម្រាប់គេរួចហើយ។**

## ខ១២ យើងត្រូវប្រព្រឹត្តដោយទៀងត្រង់ ដើម្បីលើកដំកើងព្រះ